


# សម្បត្តិបេតិកភណ្ឌឡស្លដែក នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប

# THE TANGIBLE HERITAGE OF IRON PRODUCTION SITES AT TECHO SEN RUSSEY TREB PARK OF ROYAL ACADEMY OF CAMBODIA

ដោយៈ

លោកបណ្ឌិត **ផុន កសិកា**

អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

និង

លោកបណ្ឌិត **ឈឹម សុខាន់ដារា**

*អនុប្រធានឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា*

*តេជោសែន ឫស្សីត្រឹប*

២០១៨

**សន្និសីទអន្តរជាតិ**

**ស្តីពី**

**«តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិកៈ វប្បធម៌, ប្រវត្តិ និងមោទនភាព»**

*ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨, ក្រុងសៀមរាប, ខេត្តសៀមរាប*

# «សម្បត្តិបេតិកភណ្ឌឡស្លដែក នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប»

THE TANGIBLE HERITAGE OF IRON PRODUCTION SITES AT TECHO SEN RUSSEY TREB PARK OF ROYAL ACADEMY OF CAMBODIA

បណ្ឌិត **ផុន កសិកា** និងបណ្ឌិត **ឈឹម សុខាន់ដារា**

*មន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា*

*ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានភស្តុតាងមនុស្សមករស់នៅតាំងពីយុគថ្មរំលីង ប្រហែល២០០០ឆ្នាំមុនគ្រិស្តសករាជ ប៉ុន្តែមិនមានភស្តុតាងមនុស្សរស់នៅបន្តដល់យុគក្រោយៗ ដូចជាក្នុងយុគសំរឹទ្ធ និងយុគដែកឡើយ។ ការបាត់ដានមិនមានការតាំងទីលំនៅដ៏វែងឆ្ងាយរហូតដល់ពេលមួយដែលឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ចាប់ផ្តើមមានការតាំងទីលំនៅឡើងវិញហើយប្រែក្លាយជាតំបន់ផលិតដែកធំមួយក្នុងសម័យអង្គរ។ ចាប់ពីសតវត្សរ៍ទី១១ ដល់សតវត្សរ៍ទី១៣ (ក្នុងចំណោមតំបន់ផលិតដែកផ្សេងៗទៀតដូចជានៅតំបន់ភ្នំដែក ស្រុករវៀង និងតំបន់ប្រាសាទព្រះខ័នកំពង់ស្វាយ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។*

*ការស្រាវជ្រាវបានរកឃើញទួលសន្ទុងចំនួន៥៤ទួល ស្ថិតក្នុង៥បណ្តុំដាច់ៗពីគ្នា។ ទួលសន្ទុងមានសំណល់អាចម៍ដែក និងត្រឡែកជាគំនរធំខ្ពស់ ជាភស្តុតាងបង្ហាញថាមានសកម្មភាពស្ងដែក និងសំណង់ឡស្ងដែកដែលគេបានសង់ និងប្រើប្រាស់ដើម្បីស្ងយកដែកពីរ៉ែដែក ហើយនៅតាមបណ្តុំទួលសន្ទុង ឬទួលឡស្ងដែក ពិតជាមានសន្ទុងច្រើន។*

*ការសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតអំពីឡស្លដែក រូបរាង រចនាសម្ព័ន្ធនៃឡស្ល ដែក អាយុកាលឡស្លដែកដាក់លាក់ នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា គេដោសែនឫស្សីត្រឹប នឹងត្រូវអនុវត្ត ពិសេសត្រូវធ្វើកំណាយ និងវិភាគតាមបែបវិទ្យាសាស្ត្រមួយចំនួនទៀត។*

## សេចក្តីផ្តើម

*អាណាចក្រអង្គរ ដែលមានអាយុកាលចាប់ពីសតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១៥ នៃគ្រិស្តសករាជ ត្រូវបានចាត់ទុកថា ជាសម័យកាលរុងរឿងក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយអាណាចក្រនេះមានវិសាលភាពទឹកដីគ្របដណ្តប់ដីគោក មួយភាគធំនៃតំបន់អាស៊ីអាគ្នេយ៍ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន។ ភាគឦសាននៃប្រទេសថៃ ភាគខាងត្បូងនៃប្រទេសឡាវ និងភាគខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ន[1] ជាមួយនឹងសម្បត្តិបេតិកភណ្ឌជាស្នាដៃស្ថាបត្យកម្មសិល្បៈល្អឯកនៃសំណង់ប្រាសាទបុរាណ មាននៅស្ទើរពាសពេញផ្ទៃប្រទេស។ កត្តាជាច្រើនបានជំរុញឱ្យអាណាចក្រមួយនេះរីកចម្រើនរុងរឿង រហូតក្លាយជាអាណាចក្រគ្របដណ្តប់នៅតំបន់អាស៊ីអាគ្នេយ៍ដីគោក មានដូចជា ផលិតកម្ម (កសិកម្មជាពិសេសផលិតកម្មស្រូវ) ឧស្សាហកម្ម (លោហកម្ម ផលិតកម្មដែក និងកុលាលភាជន៍ជាដើម) ស្ថាបត្យកម្ម សំណង់ ចម្លាក់ក្បាច់រចនាសម្ព័របែបជាដើម។*

*ផលិតកម្មដែកជាធាតុចូលមួយរួមចំណែកកសាងអាណាចក្រអង្គរ។ ដែកមានតួនាទីសំខាន់មួយដែរក្នុងការអភិវឌ្ឍអារ្យធម៌អង្គរ។ ដែកអាចត្រូវបានកែច្នៃយកមកធ្វើជាវត្ថុប្រើប្រាស់ក្នុងវិស័យកសិកម្ម វិស័យអាវុធយុទ្ធភណ្ឌ និងវិស័យសាងសង់ប្រាសាទធំៗផងដែរ។ ក្នុងវិស័យកសាងប្រាសាទដែលសង់អំពីថ្មភក់និងថ្មបាយក្រៀម បុព្វបុរសខ្មែរត្រូវការដែកជាចាំបាច់ក្នុងការកាត់ ដាប់ ឆ្លាក់ និងតថ្ម។ ក្នុងសតវត្សរ៍ដែលខ្មែរមានលទ្ធភាពផលិតដែកបានច្រើន ប្រាសាទថ្មធំៗជាច្រើនក៏បានកសាងក្នុងរយៈពេលនោះដែរ។ នេះជាហេតុផលមួយអាចអះអាងថា ការកសាងប្រាសាទថ្មធំៗ ត្រូវការមានដែកច្រើនសន្ធឹកសន្ធាប់[2]។*

*ការសិក្សាស្រាវជ្រាវអំពីផលិតកម្មដែកនៅប្រទេសកម្ពុជា មិនសូវផុសផុលដូចការស្រាវជ្រាវអំពីប្រាសាទនោះទេ ដោយសារវិជ្ជានេះពិបាកស្រាវជ្រាវ រួមផ្សំដោយការសិក្សាវិភាគវិទ្យាសាស្ត្រ*

---

[1] ឆាល ហាយហេម ***"វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក"*** ប្រែជាភាសាខ្មែរពី *Early Cultures of Mainland Southeast Asia*, បុរាណវិទ្យាខ្មែរ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣។

[2] Dupaigne, Bernard., *ឧស្សាហកម្មលោហធាតុនៅកម្ពុជា នាទីទេព, នាទីមនុស្ស* ក្នុង *ឧទ័យ* លេខ ៧, ឆ្នាំ២០០៧, ទំព័រ១៧៨។

បែបទំនើបទៀតផង។ ការសិក្សាស្រាវជ្រាវអំពីផលិតកម្មដែកបានធ្វើឡើងដោយលោក Bernard Dupaigne (“La Metallurgie dans l’ancien Cambodge. Travail des Dieux, Travail des hommes” Etudes Rurals, N. 125-126, Janvier-Juin 1992: 13-24) នៅឆ្នាំមុនកើតសង្គ្រាមក្នុងប្រទេស។ លោក Mitch Hendrickson រួមជាមួយលោក ផុន កសិកា បានសហការគ្នាសិក្សាស្រាវអំពីឧស្សាហកម្មអាណាចក្រអង្គរដោយសិក្សាអំពីផលិតកម្មដែក និងបច្ចេកទេសស្ងដែកនៅបាកាន (ព្រះខ័នកំពង់ស្វាយ) នៅឆ្នាំ២០០៩ (Mitch Hendrickson, ឧស្សាហកម្មអាណាចក្រអង្គរ៖ ប្រាសាទព្រះខ័នកំពង់ស្វាយ, របាយការណ៍ ឆ្នាំ២០១០)[3]។ ក្រោយមក លោកបណ្ឌិត ធុយ ចាន់ធួន (ធុយ ចាន់ធួន ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប៖ ជាឧទ្យានជាតិប្រវត្តិសាស្ត្រ វប្បធម៌ និងធម្មជាតិ ក្នុង “វេទិកាស្រាវជ្រាវវិទ្យាសាស្ត្រ លើកទី១ ប្រចាំឆ្នាំ២០១៥”, រាជបណ្ឌិត្យសភាកម្ពុជា ទំព័រ ៦៦៩-៦៧២) បានរកឃើញទួលឡស្ងដែក នៅស្រុកឆែប ហើយក្រោយមកតំបន់ទីទួលនោះ ត្រូវបានបង្កើតជាឧទ្យានមួយដោយដាក់ឈ្មោះថា **ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប** ដោយព្រះរាជក្រឹតលេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ ដែលមានផ្ទៃដីក្រឡាចំនួន១១.៤៣៥ហិចតា  និងមានទីតាំងស្ថិតក្នុងឃុំឆែប១ និងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ។ ក្រៅពីនោះ នៅមានក្រុមអ្នកស្រាវជ្រាវរបស់អាជ្ញាធរអប្សរាក៏បានសិក្សាស្រាវជ្រាវអំពីផលិតកម្មដែកនៅតំបន់អង្គរដែរ។ នៅឆ្នាំ២០១៧ ក្រុមអ្នកស្រាវជ្រាវរបស់វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ បានធ្វើការសិក្សាស្រាវជ្រាវ ស្តីពី «មរតកវប្បធម៌រូបី និងអរូបី នៅតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប» ដោយមានការចូលរួមពីមន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ផងដែរ។ នៅដើមឆ្នាំ២០១៨នេះ ក្រុមអ្នកស្រាវជ្រាវរបស់វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈបានបន្តស្រាវជ្រាវ **«សម្បត្តិបេតិកភណ្ឌវប្បធម៌រូបី និងមរតកវប្បធម៌អរូបី នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និងការសិក្សាអង្កេតមរតកវប្បធម៌អរូបីដូចគ្នានៅខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ»**។ ការសិក្សារបស់ក្រុមអ្នកស្រាវជ្រាវវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ក៏បានផ្តោតលើការស្រាវជ្រាវ

[3] Dupaigne, Bernard., *ឧស្សាហកម្មលោហធាតុនៅកម្ពុជា នាទីទេព, នាទីមនុស្ស* ក្នុង *ឧទ័យ* លេខ ៧, ឆ្នាំ២០០៧

អំពីផលិតកម្មដែកក្នុងតំបន់នេះ។ រយៈពេល២ឆ្នាំនៃការសិក្សាស្រាវជ្រាវបានរកឃើញសម្បត្តិបេតិកណ្ឌឡស្លដែកមួយចំនួន[4]។

ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានស្ថានីយបុរាណដែលជាអតីតតំបន់ស្លដែក និងផលិតឧបករណ៍ប្រើប្រាស់ធ្វើអំពីដែកដ៏ធំមួយក្នុងសម័យអង្គរ (ចាប់ពីសតវត្សរ៍ទី១១ ដល់សតវត្សរ៍ទី១៣)។ នៅក្នុងបរិវេណឧទ្យានមានទួលឡស្លដែកចំនួន៥២ ដែលស្ថិតនៅក្នុងបណ្តុំទួលឡចំនួន៥ផ្សេងគ្នា៖ ១-បណ្តុំទួលឡត្រពាំងត្រឹបមានទួលឡចំនួន១៥, ២-បណ្តុំទួលឡត្រពាំងឫស្សីត្រឹបមានទួលឡចំនួន១៧, ៣-បណ្តុំទួលឡភូមិកំបុតចាស់មានទួលឡចំនួន១០, ៤-បណ្តុំទួលឡត្រពាំងឫស្សីបល្ល័ង្កមានទួលឡចំនួន៦ និង ៥-បណ្តុំទួលឡត្រពាំងក្រសាំងមានទួលឡចំនួន៦។ ក្រៅពីនេះមានត្រពាំងសន្ទុងចំនួន២៩ ត្រពាំងបុរាណចំនួន៦៥ និងបុរាណវត្ថុមួយចំនួនដូចជា កុលាលភាជន៍ ត្រឡែកតូច ត្រឡែកធំ ផ្ទៃចបជីក ផ្ទៃដីង ចង្កឹះដងកាំបិត ដងកាំបិត និងដែកគោល ជាដើម។

### ១-បណ្តុំទួលឡស្លដែកត្រពាំងត្រឹប

បណ្តុំទួលឡត្រពាំងត្រឹបលាតសន្ធឹងលើផ្ទៃដីប្រមាណ ១០០ ០០០ ម៉ែត្រក្រឡា ប្រជុំដោយទួលឡស្លដែកមានអាយុកាលក្នុងសម័យអង្គរ (ចាប់ពីសតវត្សរ៍ទី១១ ដល់សតវត្សរ៍ទី១៣)។ បណ្តុំឡត្រពាំងត្រឹបមានទួលឡចំនួន១៥ មានសណ្ឋានរាងមូលទ្រវែងខ្លះនិងរាងមូលខ្លះ មានបណ្តោយចាប់ពី ២១ម៉ែត្រ ទៅ ៧៣ម៉ែត្រ មានទទឹងចាប់ពី ១៣ម៉ែត្រ ទៅ ៤២ម៉ែត្រ និង កម្ពស់ចាប់ពី ០,៧ ម៉ែត្រ ទៅ ២,២០ ម៉ែត្រ។ ទួលឡមានសំណល់គំនរអាចម៍ដែក មានបំណែកជញ្ជាំងឡ បំណែកត្រឡែកតូច និងបំណែកត្រឡែកធំ។ នៅតាមបណ្តាទួលឡមានទំហំធំ ហើយខ្ពស់មានសំណល់គំនរអាចម៍ដែកពណ៌ខ្មៅ ចំណែកឯនៅតាមបណ្តាទួលឡមានទំហំតូច ហើយទាប មានសំណល់គំនរអាចម៍ដែកពណ៌ផ្កាឈូក។

បណ្តុំទួលឡត្រពាំងត្រឹបមានត្រពាំងសន្ទុងចំនួន១២ មានបណ្តោយចាប់ពី ៧ម៉ែត្រ ទៅ ៣៣ម៉ែត្រ និងមានទទឹងចាប់ពី ៧ម៉ែត្រ ទៅ ២៨ម៉ែត្រ ច្រើនស្ថិតនៅក្បែរជើងទួលឡ ជាត្រពាំងមានទំហំតូចនិងជម្រៅរាក់ កើតឡើងដោយសារគេជីកយកដីឥដ្ឋធ្វើឡនិងធ្វើត្រឡែក។ វត្ថុបុរាណមួយចំនួន

[4] ភាសាអ្នកស្រុកហៅឡស្លដែកថា "សន្លុង"។

ដូចជា ផ្ទៃចបជីក ផ្ទៃដីផ្ទាំង ចង្កឹះដងកាំបិត ដងកាំបិត និង ដែកគោល ដែលបានរកឃើញនៅបណ្តុំទួល ត្រពាំងត្រឹប បង្ហាញអំពីសកម្មភាពជំបូស្មិតដែកស្របគ្នានឹងសកម្មភាពស្ងដែកដែរ។



រូបលេខ១៖ ទួលឡត្រពាំងត្រឹប១

## ២-បណ្តុំទួលឡស្លដែកត្រពាំងឫស្សីត្រឹប

បណ្តុំទួលឡត្រពាំងឫស្សីត្រឹបលាតសន្ធឹងលើផ្ទៃដីប្រមាណ ៣២៥ ០០០ ម៉ែត្រក្រឡា ប្រជុំដោយទួលឡ មានអាយុកាលក្នុងសម័យអង្គរ (ចាប់ពីសតវត្សរ៍ទី១១ ដល់សតវត្សរ៍ទី១៣)។ បណ្តុំទួលឡត្រពាំងឫស្សីត្រឹបមានទួលឡចំនួន១៧ ដែលភាគច្រើនមានសណ្ឋានរាងមូលទ្រវែង និងភាគតិចមានសណ្ឋានរាងមូល មានបណ្តោយចាប់ពី ២៥ម៉ែត្រ ទៅ ៩២ម៉ែត្រ មានទទឹងចាប់ពី ១៨ម៉ែត្រ ទៅ ៦២ម៉ែត្រ និងកម្ពស់ចាប់ពី ០,៥ ម៉ែត្រ ទៅ ៤,៤០ ម៉ែត្រ។ ទួលឡទាំងនេះមានសំណល់គំនរអាចម៍ដែកពណ៌ខ្មៅ មានបំណែកជញ្ជាំងឡ បំណែកត្រឡែកតូច និងបំណែកត្រឡែកធំ។

បណ្តុំទួលឡត្រពាំងឫស្សីត្រឹបមានត្រពាំងសន្ទុងចំនួន១៧ មានបណ្តោយចាប់ពី ៨ម៉ែត្រ ទៅ ២៩ម៉ែត្រ និងមានទទឹងចាប់ពី ៧ម៉ែត្រ ទៅ ២៨ម៉ែត្រ ច្រើនស្ថិតនៅក្បែរជើងទួលឡ ជាត្រពាំងមានទំហំតូច និងជម្រៅរាក់ កើតឡើងដោយសារគេជីកយកដីឥដ្ឋធ្វើឡ និងធ្វើត្រឡែក។

ទួលឡមានពីរប្រភេទគឺប្រភេទធំ ខ្ពស់ ដែលមានអាចម៍ដែកពណ៌ខ្មៅ និងទួលឡប្រភេទទំហំតូច និងទាបមានអាចម៍ដែកពណ៌ផ្កាឈូក។

បណ្តុំទួលឡត្រពាំងឫស្សីត្រឹបមានត្រពាំងចំនួន៤ សម្រាប់ប្រើប្រាស់តម្រូវការផ្សេងៗរបស់មនុស្ស និងត្រពាំងសន្ទុងចំនួន១៥ មានទំហំ និងជម្រៅខុសៗគ្នា។ លក្ខណៈត្រពាំងទាំងនេះមិនខុសគ្នានឹងត្រពាំងនៅបណ្តុំទួលឡត្រពាំងត្រឹបដែរ គឺគេច្រើនជីកនៅជាប់នឹងទួលឡដើម្បីងាយស្រួលក្នុងការយកដី និងទឹកមកប្រើប្រាស់ក្នុងតម្រូវការស្ងដែក។



រូបលេខ២៖ ទួលឡត្រពាំងឫស្សីត្រើប៥

## ៣-បណ្តុំទួលឡស្លដែកភូមិកំបុតចាស់

បណ្តុំទួលឡទី៣ស្ថិតនៅភូមិកំបុតចាស់ នៅភាគខាងកើតនៃឧទ្យាន។ សណ្ឋាននៃការរៀបចំដែនដីសម្រាប់ផលិតកម្មស្លដែកនៅបណ្តុំទួលឡនេះក៏ដូចគ្នានឹងបណ្តុំឡមុនៗដែរ ដោយបណ្តុំឡស្ថិតនៅភាគនិរតីនៃត្រពាំងភូមិកំបុតចាស់។ បណ្តុំឡភូមិកំបុតចំនួន១០ឡ និងមានឡប្រភេទតូចរាបនិងធំខ្ពស់ដែរ ដែលមានអាចម៍ដែកពណ៌ផ្កាឈូកក៏ច្រើន។




រូបលេខ៣៖ រូបភាពពីលើអាកាសនៃបណ្តុំទួលឡភូមិកំបុតចាស់ (រូបភាពGoogle Earth)

## ៤-បណ្ដុំទួលឡត្រពាំងឫស្សីបល្ល័ង្គ

*បណ្ដុំទួលឡទី៤ ស្ថិតនៅនិរតីត្រពាំង ឫស្សីបល្ល័ង្គដែលស្ថិតនៅចុងភាគខាងលិចឧទ្យាន ចម្ងាយប្រមាណ៨គីឡូម៉ែត្រពីត្រពាំងត្រើប មានទួលឡចំនួន៦។ ក្នុងចំណោមទួលឡទាំង៦មានទាំងឡាពប និងឡខ្ពស់ដែលមានអាចម៍ដែកពណ៌ផ្កាឈូក និងពណ៌ខ្មៅ។*




រូបលេខ៤៖ រូបភាពពីលើអាកាសនៃបណ្ដុំទួលឡត្រពាំងឫស្សីបល្ល័ង្គ (រូបភាពGoogle Earth)

## ៥-បណ្ដុំទួលឡត្រពាំងក្រសាំង

*ទីតាំងបណ្ដុំទួលឡទី៥ មានទួលឡ៦ស្ថិតនៅភាគនិរតីត្រពាំងក្រសាំង និងនៅភាគពាយព្យត្រពាំងត្រឡាត់សង្កែ។ បណ្ដុំទួលឡត្រពាំងក្រសាំងស្ថិតនៅចម្ងាយ១គីឡូម៉ែត្រខាងលិចត្រពាំងត្រើប ។*




រូបលេខ៥៖ រូបភាពពីលើអាកាសបង្ហាញពីបណ្តុំទួលឡត្រពាំងក្រសាំង (រូបភាពGoogle Earth)

ក្រៅពីទួលឡស្លដែកដែលរកឃើញទាំងប៉ុន្មាន នៅមានបុរាណវត្ថុមួយចំនួនដូចជា កុលាលភាជន៍ មានតាំងពីកុលាលភាជន៍ខ្មែរ និងកុលាលភាជន៍ចិនទៀតផង។ កុលាលភាជន៍ខ្មែរជាកុលាលភាជន៍ប្រភេទផុយផង និងប្រភេទរឹងផង (មើលទៅដូចជាថ្ម ដែលភាសាអង់គ្លេសហៅថា stoneware)។ ប្រភេទកុលាលភាជន៍ពិបាកសិក្សាវិភាគរកអាយុកាល និងទីតាំងផលិត ព្រោះក្នុងប្រវត្តិនៃការផលិតកុលាលភាជន៍ខ្មែរតែងមានកុលាលភាជន៍ ផុយរហូតមកមិនដែលដាច់។ ពិសេសនោះ កុលាលភាជន៍ផុយតាំងពីសម័យបុរេប្រវត្តិសាស្ត្រ រហូតមកដល់សម័យបច្ចុប្បន្នមានលក្ខណៈ និងសណ្ឋានស្រដៀងគ្នា។ កន្លងមកអ្នកស្រាវជ្រាវបុរាណវត្ថុវិទ្យាខ្មែរនៅឡើយមិនទាន់សិក្សាបែងចែកកុលាលភាជន៍ផុយទៅតាមកាលសម័យឱ្យបានជាក់ច្បាស់នៅឡើយទេ។ ផ្ទុយទៅវិញ កុលាលភាជន៍រឹងត្រូវបានអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិសិក្សាស្រាវជ្រាវច្រើន និងមានការកំណត់អាយុកាល និងទីតាំងផលិត។ ដូចជាកុលាលភាជន៍ដែលប្រមូលបានពីបណ្តុំឡស្លដែកក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានកុលាលភាជន៍យកពីស្ថានីយជើងឯកដែលមានកាលបរិច្ឆេទច្បាស់លាស់ក្នុងសតវត្សរ៍ទី១០-១៣ នៃគ្រិស្តសករាជ។ នៅមានកុលាលភាជន៍មកពីស្ថានីយបុរីម្យដែលមានកាល

បរិច្ឆេទក្នុងសតវត្សរ៍ទី១១នៃគ្រិស្តសករាជក៏បានរកឃើញនៅបណ្តុំទួលឡទាំងនេះដែរ។ កុលាលភាជន៍រឹងទាំងនេះ ក៏មានប្រភេទមកពីតំបន់អង្គរគឺមកពីស្ថានីយទ័ពជ័យដែលមានកាលបរិច្ឆេទក្នុងចុងសតវត្សរ៍ទី១៣។



រូបលេខ៦៖ កុលាលភាជន៍ផុយដែលរកឃើញនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប



រូបលេខ៧៖ កុលាលភាជន៍រឹងមានស្រទាប់រលោងពណ៌ត្នោតចាស់



រូបលេខ៨៖ កុលាលភាជន៍រឹងគ្មានស្រទាប់រលោង ដែលប្រហែលនាំចូលពីស្ថានីយជើងឯក



រូបលេខ៩៖ បំណែកខ្លួនកុលាលភាជន៍រឹងមកពីស្ថានីយទ័ពជ័យ

*ត្រឡែកក៏បានរកឃើញក្នុងបណ្តុំទួលឡស្ងដែកដែរ។ ត្រឡែកមានរូងរាងជាបំពង់មូលទ្រវែង មានទំហំខុសគ្នា។ ត្រឡែកចែកជា២ប្រភេទខុសគ្នា គឺប្រភេទត្រឡែកធំ និងប្រភេទត្រឡែកតូច។ តាមការសិក្សាវិភាគត្រឡែកធំ យើងអាចសន្និដ្ឋានជាបឋមថា ត្រឡែកសម្រាប់តភ្ជាប់ពីស្នប់ខ្យល់ទៅជញ្ជាំងឡ មានតួនាទីជាបំពង់នាំខ្យល់ពីស្នប់ចូលទៅក្នុងឡ។*




រូបលេខ១០៖ ត្រឡែកធំ

*អាចម៍ដែកក៏ជាវត្ថុបុរាណដែលរកឃើញក្នុងបណ្តុំទួលឡស្ងដែកដែរ។ អាចម៍ដែកគឺជាកាកសំណល់បានពីការស្ងដែក។ អាចម៍ដែកដែលប្រមូលបានមានពីរប្រភេទគឺ អាចម៍ដែកពណ៌ខ្មៅ និងអាចម៍ដែកពណ៌ផ្កាឈូក។*



រូបលេខ១១៖ អាចម៍ដែកពណ៌ខ្មៅ



រូបលេខ១២៖ អាចម៍ដែកពណ៌ផ្កាឈូក

រឹតតែពិសេសទៅទៀត ក្រុមការងារស្រាវជ្រាវក៏បានរកឃើញឧបករណ៍ដែកក្នុងបណ្តុំទួលឡស្លដែកតាមរយៈការសិក្សាផ្ទៃលើ (surface collection) មិនមែនបានពីការធ្វើកំណាយទេ។ ឧបករណ៍ដែកទាំងអស់នោះមានដូចជា៖ ដងចបជីក១ ផ្លែដឹង១០ ដងកាំបិត១ និងចង្កុំកាំបិត៣ និងដែកគោល ២។ នេះបញ្ជាក់ថា សកម្មភាពស្លដែក និងស្មិតដែកទៅជាឧបករណ៍ក៏មាននៅទីនោះដែរ។



រូបលេខ១៣៖ ឧបករណ៍ដែកជាប្រភេទផ្លែចបជីក

## សន្និដ្ឋាន

ទួលឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ជាសម្បត្តិបេតិកភណ្ឌបង្ហាញច្បាស់ថា ឧស្សាហកម្មផលិតដែកបានកើតឡើងក្នុងសម័យអង្គរ (ចាប់ពីសតវត្សរ៍ទី១១ ដល់សតវត្សរ៍ទី១៣) ក្នុងពេលកម្ពុជាក្លាយជាអាណាចក្រក្នុងតំបន់អាស៊ីអាគ្នេយ៍ដីគោក។ នៅពេលតម្រូវការដែកកាន់តែច្រើនឡើងសម្រាប់ផ្គត់ផ្គង់អាណាចក្រមួយនេះ តំបន់ឫស្សីត្រឹប និងតំបន់ជុំវិញ (ក្នុងខេត្តព្រះវិហារ) ក៏បានដើរតួនាទីសំខាន់ក្នុងការផលិត ដែក ដោយមូលហេតុមានរ៉ែដែក និងធនធានធម្មជាតិសម្រាប់ស្លយកដែកបាន។

ការសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនៅក្នុងតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប រួមទាំងការធ្វើកំណាយ និងការវិភាគតាមបែបវិទ្យាសាស្ត្រមួយ

*ចំនួនទៀត ត្រូវតែអនុវត្តនៅថ្ងៃអនាគតដើម្បីបញ្ជាក់ពីការតាំងទីលំនៅដ៏ជាក់លាក់របស់មនុស្ស ក្នុងយុគថ្មរំលីង អាយុកាលរបស់ស្ថានីយតាមរយៈការវិភាគវិទ្យុសកម្មធ្យូង និងចំណោទបញ្ហាស្រាវជ្រាវមួយចំនួនទៀត ពិសេសការសិក្សាស្រាវជ្រាវនិងធ្វើកំណាយដើម្បីស្វែងយល់អំពីរចនាសម្ព័ន្ធឡស្លដែក បច្ចេកទេស ផលិតដែក និងអាយុកាលនៃផលិតកម្មដែកនៅឧទ្យាននេះជាក់លាក់តាមការធ្វើវិភាគវិទ្យុសកម្មធ្យូង និងការធ្វើវិភាគតាមវិធីសាស្ត្រវិទ្យាសាស្ត្រផ្សេងៗទៀត ក្នុងការទាញយកព័ត៌មានក៏ដូចជាទិន្នន័យទាក់ទងនឹងផលិតកម្មដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប។*

## ឯកសារពិគ្រោះ

ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

ឆាល ហាយហេម, វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក បកប្រែជាភាសាអង់គ្លេសពីសៀវភៅឈ្មោះ «Early Culture of Mainland Southeast Asia», អង្គការបុរាណវិទ្យាខ្មែរ និងរាជបណ្ឌិត្យសភាកម្ពុជា, ទំព័រ ២៧, ២០១៣។

ធុយ ចាន់ធួន, *ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប៖ ជាឧទ្យានជាតិប្រវត្តិសាស្ត្រ វប្បធម៌ និងធម្មជាតិ* ក្នុង «វេទិកាស្រាវជ្រាវវិទ្យាសាស្ត្រ លើកទី១ ប្រចាំឆ្នាំ២០១៥», រាជបណ្ឌិត្យសភាកម្ពុជា ទំព័រ ៦៦៩-៦៧២

នូ ចាន់សុភី, ផុន កសិកា, ប្រែង ពិសិដ្ឋ, ម៉ុល វាសនា, ជ័យ រតនា, ហឿង សុជាស់, សរ សិលា, យ៉ាន់ វិការតន៍, ឈឹម សុខាន់ដាក, សួន សុភា, ស្រី សីហា, សាល់ ខាន់ «មរតកវប្បធម៌រូបី និងអរូបីនៅតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប», វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១៧។

ហេង សុផាឌី និង ហេង ថាន, បុរេប្រវត្តិសាស្ត្រ ៖ ប្រវត្តិនៃការសិក្សាស្រាវនិងបញ្ជីស្ថានីយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ទំព័រ៨២, ២០១៤។

Albrecht, Gerd., *Circular Earthwork Krek 52/62: Recent Research on the Prehistory of Cambodia*, in Asian Perspective, Vol. 39, No 1-2, 2001.

Dupaigne, Bernard., *ឧស្សាហកម្មលោហធាតុនៅកម្ពុជា នាទីទេព, នាទីមនុស្ស* ក្នុង *ឧទ័យ* លេខ ៧, ឆ្នាំ២០០៧

Hendrickson, Mitch., ឧស្សាហកម្មអាណាចក្រអង្គរ៖ ប្រាសាទព្រះខ័នកំពង់ស្វាយ, របាយការណ៍ ឆ្នាំ២០១០

Higham, Charles F. W., First Farmers in Mainland Southeast Asia, *JOURNAL OF INDO-PACIFIC ARCHAEOLOGY,* 41, (2017):13-21.

Ly Vanna, *Rice Remains in the Early Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodia.* In Aséanie, 2002, pp. 13-34.

Mourer, Roland., Laang Spean and the Prehistory of Cambodia, in Modern Quaternary Research in Southeast Asia, January 1977.